# លលក



ថ្ងៃត្រង់  វាលស្រែក្ដៅខ្លាំង  ...
ដូចជាភ្លើងភ្នក់មួយយ៉ាងធំ
ព្រះអាទិត្យចិត្តឃោរឃៅដុតកម្ដៅចស្មៅនិងជញ្ជ្រាំង
ចំហាយខ្យល់បក់ភិបៗលើទឹកល្អក់ក្នុងត្រពាំង
ដែលមានកុកសម្គមមួយចាំចាប់កំពិសដោយសំងំ។

សត្វនានាស្ងាត់មាត់ជ្រងំ  ...
ចង្រិតដែលជាពិរម្យ
របស់ស្រុកស្រែនោះសោតក៏ជ្រកពួនដោយភាន់ភាំង
អ្នកគង្វាលគោដេក  ដៃគងថ្ងាស  ស្រមុកគ្រាំងៗ
ក្រោមដើមអំពិលដ៏មានម្លប់ត្រជាក់ត្រជុំ។

នៅវេលាដែលក្ដៅហប់ទូទៅសព្វវាលព្រៃព្រឹក្ស  ...
មានលលកមួយហើរមកទំលើមែកឈើដែលឥតស្លឹក
ហើយបក្សីនោះតាំងស្រែកច្រៀងគ្រលួច  ពិរោះឥតបី
ក្នុងតុណ្ហីភាពសំលេងនោះសែនរាបសាថ្លាដូចចរណៃ
មកញ៉ាំងអ្នកដែលសន្ធឹងខ្នងផ្ទាល់ដីឱ្យស្រមៃ



ឃើញវិមានឋានសួគ៌ានិងកញ្ញាល្អប្រិមប្រិយ  ...។

ឆ្នូ  ហាច